# តាំ តាំ



## ប្រវត្តិពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ

តម្លៃ ៦០០០ រៀល

## History of Kan Ben and PHCHUM BEN

# ប្រវត្តិពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ[១]

## History of Kan Ben and Phchum Ben Festival[1]



គម្ពីរធម្មបទបានសំដែងថា ការដែលអ្នកកាន់ព្រះពុទ្ធសាសនាតែងជឿថាមានពពួកប្រេត[២]នោះ ព្រោះមានរឿងមួយបានតំណាលថា :

កាលកន្លងទៅ ក្នុងសាសនានៃព្រះពុទ្ធនាម **ផុស្សៈ (បុស្សៈ)** ។ កាលនោះ ព្រះបាទ**ពិម្ពិសារ**កើតជានាយស្មៀនរបស់ព្រះរាជាមួយព្រះអង្គ ព្រមទាំងពួកញាតិជាច្រើនមានតួនាទីជាអ្នកចាត់ចែងធ្វើចង្ហាន់ប្រគេនព្រះសង្ឃ មានព្រះពុទ្ធព្រះនាម **ផុស្សៈ** ជាប្រធានចំនួន៣ខែ នៅក្នុងអារាមនៃព្រះសម្មាសម្ពុទ្ធដោយសទ្ធាបរិសុទ្ធ ។

The precept treatise stipulated that the Buddhist followers believe that there are evil spirits[2], for there is a legend which is told as follows:

In the era of the Buddha named **Phossa** (**Bossa**), **Pimpisa**, who reincarnated as a chief clerk of a King, and many relatives managed the food offerings for the disciples, when in holy faith the Buddha named "**Phossa**" was the head of his monastery for three months.

កាលដែលទៅចាត់ចែងធ្វើចង្ហាន់នោះ ញាតិខ្លះក៏មានកូនតូចៗទៅជាមួយ ហើយកូនតូចៗចេះតែទារហូបនំចំណី ។ ញាតិទាំងនោះក៏មានចិត្តប្រមាថ ដោយយកចង្ហាន់សម្រាប់ព្រះពុទ្ធ និងព្រះភិក្ខុសង្ឃមកបញ្ចុកកូន ហើយក៏ហូបខ្លួនឯងខ្លះតាមចំណង់ ចំណែកចង្ហាន់ដែលសេសសល់ទាំងប៉ុន្មាន ក៏យកទៅប្រគេនភិក្ខុសង្ឃ ថ្វាយព្រះពុទ្ធជាក្រោយ ។

When going to prepare the offerings, some relatives had small children go with them, and those children asked for food in the offerings. The relatives were scornful, for the food for the Buddha and the disciples was taken for their children and themselves, while only the remains were offered to the Buddha and the disciples.



លុះស្លាប់ពីជាតិជាមនុស្សនេះទៅ អ្នកទាំងនោះក៏បានទៅកើតជាប្រេតមួយពួក ទទួលនូវការស្រេកឃ្លានជាអនេក ។ ម្នាក់ៗស្រែកយំរកអាហារ ទឹកភ្នែកហូរជោកលើប្រាណស្គមស្គាំង ។ ប្រេតខ្លះ ដោយការស្រេកឃ្លានទ្រាំមិនបាន ចង់ស្លាប់ក៏ស្លាប់មិនកើត ក៏ចាប់ហែកសាច់ខ្លួនឯង ចាក់យកឈាមមកស៊ីគួរឱ្យសង្វេគ ។ ឯពួកប្រេតខ្លះទៀត ក៏ស៊ីគំរង់ដែលស្អុយរលួយ បៀមដោយខ្ទុះឈាម ក្រមរដំបៅធ្វើជាអាហារ ។

When they died, they became a group of evil creatures that were always hungry. They were all crying with hunger, with tears covering their skinny bodies. Some evil creatures could not stand the hunger. They wanted to end their lives, but they could not have it ended. They tore their own flesh and suffered while getting blood for food. And some other evil creatures ate carrion, and held pus in their mouths, and scabs.



ដោយសេចក្ដីស្រេកឃ្លានគ្របសង្កត់ខ្លាំងពេក ពួកប្រេតទាំងនោះក៏នាំគ្នាចូលទៅកាន់សំណាក់ព្រះពុទ្ធព្រះនាម**កកុសន្ធោ** ហើយយំអង្វរសុំអាហារ តែព្រះពុទ្ធជាម្ចាស់មានព្រះបន្ទូលថា "ម្នាលអ្នកទាំងឡាយ ! ក្នុងសាសនារបស់យើងនេះ អ្នកទាំងឡាយនឹងមិនបានបរិភោគអាហារអ្វីឡើយ" ។ ពួកប្រេតទាំងនោះបានឮហើយក៏នាំគ្នាស្រែកទ្រហោយំ ហើយសួរថា

Since they were overwhelmed with hunger, they went into the dwelling place of the Buddha under the name of **Kakosunthoa** and begged him for food. The Buddha said, "Folk, in our religion, you will not have any food." Hearing this, they burst into tears and asked,



"បពិត្រព្រះពុទ្ធជាម្ចាស់ ! តើពេលណាទើបពួកយើងបានទទួលអាហារឆ្ងាញ់នឹងគេ ?" ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់តបថា "តពីនេះទៅផែនដីនឹងដុះមួយយោជន៍[៣] ព្រះពុទ្ធមួយអង្គទៀតព្រះនាម**កោនាគមនោ** នឹងត្រាស់ដឹងក្នុងលោក ! អ្នកទាំងអស់ចាំសួរព្រះពុទ្ធអង្គនោះចុះ" ។

"My Buddha, when can we eat some delicious food?" The Buddha responded, "From now till the earth grows for one **yoach** (approximately 16km)[3], there will be another reincarnation of Buddha under the name **Koanea Keakmono** who will be enlightened in the world. You will have to wait and ask that Buddha."



ពេលដែលផែនដីដុះចំនួនមួយយោជន៍ ព្រះពុទ្ធព្រះនាម**កោនាគមនោ**ក៏ត្រាស់ដឹងឡើង ពួកប្រេតទាំងនោះក៏នាំគ្នាចូលទៅសាកសួរ "តើនៅពេលណាទើបពួកយើងបានអាហារបរិភោគ ?" ។ ព្រះពុទ្ធទ្រង់ឆ្លើយ "អ្នកទាំងឡាយចាំសួរព្រះពុទ្ធព្រះនាម**កស្សបោ**ដែលនឹងត្រាស់ដឹងខាងក្រោយ" ។ លុះព្រះសម្មាសម្ពុទ្ធព្រះនាម**កស្សបោ**ទ្រង់ត្រាស់ដឹងក្នុងលោក ពួកប្រេតទាំងនោះក៏ចូលទៅសាកសួរទៀត ព្រះអង្គទ្រង់ត្រាស់ថា

When the earth had grown for one **yoach** (approximately 16km) and the Buddha under the name **Koanea Keakmono** got enlightened, those evil creatures went in and asked him, "When can we have some food?" The Buddha responded, "You folk have to wait and ask the next reincarnation of Buddha under the name **Kassaboa** who will be enlightened in this world. The evil creatures then went to ask the enlightened Buddha in the next reincarnation,



"ម្នាលអ្នកទាំងឡាយ មិនទាន់បានបរិភោគអាហារក្នុងសាសនាតថាគតទេ ! តែអ្នកទាំងឡាយនឹងបានបរិភោគក្នុងសាសនានៃព្រះពុទ្ធព្រះនាម**គោតម** ដែលនឹងត្រាស់ដឹងខាងក្រោយ ។ នៅពេលនោះញាតិរបស់អ្នកជាព្រះរាជាព្រះនាមព្រះបាទ**ពិម្ពិសារ** នឹងឧទ្ទិសទានដល់អ្នកទាំងឡាយ" ។

"Folk, you cannot have food in the religion of this reincarnation of the Buddha. However, you will have food in the religion of the following Buddha reincarnation under the name **Koadom** who will be enlightened. At that time, your relative, King **Pimpisa**, will dedicate the food to you folk."



ពួកប្រេតទាំងនោះ កាលស្តាប់ហើយក៏នាំគ្នារីករាយឥតឧបមា ព្រោះរំពឹងថានឹងបានអាហារបរិភោគនៅពេលឆាប់ៗនេះមិនខាន ។

លុះព្រះពុទ្ធព្រះនាម**សមណគោតម**ជាបរមគ្រូនៃយើងសព្វថ្ងៃបានត្រាស់ដឹងឡើង ពួកប្រេតទាំងនោះក៏ចូលមកកាន់សំណាក់ព្រះពុទ្ធនៅវេលាទៀបភ្លឺ ហើយសួររកអាហារបរិភោគ ។

Having heard that, the evil creatures were so happy, for they expected that they would have food soon."

When the Buddha in the reincarnation as **Samanak Koadom**, our present teacher, became enlightened, the evil creatures went into the dwelling place of Buddha at dawn and asked for food.



ព្រះពុទ្ធទ្រង់មានបន្ទូលតបដោយទឹកព្រះភក្ត្រញញឹមថា "ក្នុងសាសនា**គោតម** អ្នកទាំងឡាយបានបរិភោគហើយ !" ។ ពួកប្រេតទាំងនោះទូលត្រលប់ទៅវិញថា "ពួកយើងរង់ចាំអស់ច្រើនជំនាន់ព្រះពុទ្ធហើយ មិនឃើញអាហារសម្រាប់ពួកយើង តើអាហារនោះនៅឯណា ? ឯណាក្លិនក្រអូបនៃបាយពណ៌សក្បុសដែលយើងចង់ស្រង់ក្លិន ?" ។ ព្រះពុទ្ធទ្រង់ឆ្លើយថា

Buddha answered with a smile, "In the religion of the reincarnation as **Koadom**, you can have food." The evil creatures responded, "We have been waiting for many reincarnations of Buddha and we have never seen any food for us. Where's the food? Where is the scent of the white rice we want to smell?" The Buddha replied,



"លុះណាតែព្រះបាទពិម្ពិសារ ជាញាតិរបស់អ្នករាល់គ្នាចាត់ចែងអាហារប្រគេន
ព្រះសង្ឃក្នុងសាសនានេះ ទើបអ្នកទាំងអស់គ្នាបានបរិភោគ" ។

ក្នុងវស្សានរដូវ មានភ្លៀងធ្លាក់ជោកជាំ ។ ស្លឹកឈើទាំងឡាយសឹងទ្រោមចុះដោយសារ
ទឹកភ្លៀង ។ ពួកប្រេតទាំងនោះ ក៏នាំគ្នាចូលទៅកាន់សំណាក់ព្រះបាទពិម្ពិសារ នៅវេលា
ពាក់កណ្ដាលរាត្រី ហើយនាំគ្នាស្រែកផង យំផងដោយសំលេងគួរឱ្យខ្លាច និងគួរឱ្យសង្វេគ ។
ព្រះបាទពិម្ពិសារបានឮសំលេងនោះហើយ ក៏មានចិត្តតក់ស្លុតរន្ធត់យ៉ាងខ្លាំង ។

"You cannot have food unless your relative, King **Pimpisa**, managed the food offerings for the monks in this religion."

In the rainy season, there was a lot of rain. The tree leaves were weighed down by the rain. The evil creatures went to the residence of King **Pimpisa** at midnight and made cried dreadfully in suffering. Hearing that, the King was very frightened.



លុះព្រឹកឡើង ទ្រង់ក៏ប្រញាប់ប្រញាល់ទៅក្រាបថ្វាយបង្គំទូលសួរព្រះពុទ្ធជាម្ចាស់ពីហេតុការណ៍ដ៏ចម្លែកនោះ ។ ព្រះពុទ្ធជាម្ចាស់ត្រាស់តបថា "នោះជាសំឡេងញាតិរបស់មហារាជដែលបានកើតជាប្រេត ហើយទទួលការអត់ឃ្លានជាច្រើនជំនាន់ព្រះពុទ្ធមកហើយ" ។ ព្រះរាជាទ្រង់សួរទៀត "ចុះទូលបង្គំធ្វើអ្វី ដើម្បីកុំឱ្យអ្នកទាំងនោះមកស្រែកគួរឱ្យខ្លាចទៀតនោះ ?" ។ ព្រះពុទ្ធបានណែនាំព្រះរាជាឱ្យរៀបចំចង្ហាន់ប្រគេនភិក្ខុសង្ឃ ដើម្បីឧទ្ទិសចំពោះពួកគេ នោះពួកគេនឹងបានទទួលហើយ ។

The following morning, the King rushed to meet the Buddha and tell him about the strange event. The Buddha responded, "That was the voice of your relatives who were reincarnated as evil creatures, and they have been living in hunger for many reincarnations of Buddha." The King continued, "What am I supposed to do to stop their dreadful crying?" The Buddha told him to arrange food offerings to the monks and to dedicate the food for them so that they would get it.



វេលាបន្ទាប់ ព្រះបាទ**ពិម្ពិសារ**ក៏រៀបចំចាត់ចែងចង្ហាន់ដោយសទ្ធាប្រគេនភិក្ខុសង្ឃ ៥០០អង្គ មានព្រះពុទ្ធជាប្រធាន ។ កាលព្រះសម្មាសម្ពុទ្ធ និងព្រះភិក្ខុសង្ឃទទួលចង្ហាន់ហើយ ព្រះអង្គទ្រង់អនុមោទនានូវទានរបស់ព្រះរាជា ដោយសម្ដែងតិរោកុឌ្ឌសូត្រ ។ ពេលនោះព្រះបាទ**ពិម្ពិសារ**ក៏ឧទ្ទិសទាននោះដល់ពួកប្រេតជាញាតិ ដូចបានស្ដាប់ព្រះពុទ្ធដីកាខាងដើម ។ ប្រេតទាំងនោះ អនុមោទនានូវចង្ហាន់ដែលព្រះរាជាទ្រង់ឧទ្ទិសឱ្យ ក៏ក្លាយទៅជាម្ហូបអាហារទិព្វ បរិភោគយ៉ាងរីករាយរកអ្វីប្រៀបមិនបាន ។

Later, the King, in good faith, had the food arranged for 500 monks with Buddha as the leader. When the Buddha and monks had the food, they expressed their joy over the offerings made by the King dedicating to them by performing **Deroakoddasot** (praying for the funeral). Then the King **Pimpisa** dedicated the offerings to his relatives as told by the Buddha. Those evil creatures expressed joy at receiving food dedicated by the King. It became magic food, and they ate it happily.



នៅរាត្រីបន្ទាប់ ពួកប្រេតជាញាតិទាំងនោះសុទ្ធតែមានភាពរីករាយព្រោះបានអាហារ ។ ពួកគេបានចេញមកបង្ហាញខ្លួនឱ្យព្រះបាទ**ពិម្ពិសារ**បានឃើញ នៅតាមបង្អួចខ្លះ នៅតាមសសរខ្លះ នៅតាមច្រកទ្វារប្រាសាទខ្លះ និងនៅលើធ្នឹមខ្លះ ហើយពោលពាក្យអរគុណ តែរូបកាយរបស់ពួកប្រេតទាំងនោះសុទ្ធតែអាក្រាត និងមានក្លិនមិនគួរឱ្យចេតនា ។ ប្រេតខ្លះមានមាត់ធំ ច្រមុះតូច ពោះធំមាត់តូច គួរឱ្យខ្លាចពន់ពេក ។ ព្រះបាទ**ពិម្ពិសារ**ទ្រង់ទតឃើញហើយក៏មានសេចក្តីតក់ស្លុត អង្វរឱ្យពួកប្រេតទាំងនោះចេញទៅ ។

The following night, the evil creatures were all happy, they had food. They showed up through windows, pillars, doors and roof beams, to thank the King **Pimpisa**, but they were naked and smelled unpleasant. Some of them had big mouths, small noses, big stomachs and small mouths, which was terrifying. When King **Pimpisa** saw that, he became very frightened and pleaded with them to leave.



លុះព្រឹកឡើង ទ្រង់ក៏នាំហេតុការណ៍នោះមកទូលសួរព្រះពុទ្ធជាម្ចាស់ ។ ព្រះពុទ្ធជាម្ចាស់ត្រាស់តបថា “ពួកគេបានទទួលអាហារហើយ តែមហារាជនៅមិនទាន់ធ្វើគ្រឿងគ្របដណ្តប់ប្រគេនព្រះភិក្ខុសង្ឃ ទើបពួកប្រេតទាំងនោះមកបង្ហាញខ្លួនក្នុងអាការៈអាក្រាតកាយដូច្នេះ” ។ បានដំណឹងហើយ ព្រះបាទ**ពិម្ពិសារ**ក៏ប្រញាប់ប្រញាល់រៀបចាត់ចែងធ្វើគ្រឿងគ្របដណ្តប់ប្រគេនព្រះភិក្ខុសង្ឃ ហើយបានឧទ្ទិសចំពោះញាតិទាំងនោះដោយសទ្ធាចិត្តស្អាតបរិសុទ្ធ ។

The following morning, the King told the Buddha about the matter. The Buddha responded, “They have received food, but you have not offered clothing to the monks; that's why they showed up naked like that.” Having been told this, the King rushed to have clothing organized to be offered to the monks. And he dedicated the clothing to his relatives with pure good faith.



ដល់រាត្រីទីបី ស្រាប់តែពួកប្រេតទាំងនោះមកបង្ហាញខ្លួនម្ដងទៀត តែលើកនេះ ពួកគេសុទ្ធតែមានសំលៀកបំពាក់ស្អាតបាតបាំងជិតរាងកាយ និងមានពន្លឺចាំងចេញពីកាយដូចជារស្មីនៃមាស ។ ពួកគេបានពោលថ្វាយពរគ្រប់យ៉ាងចំពោះព្រះបាទ**ពិម្ពិសារ** រួចក៏រសាត់បាត់ទៅហោង ។

The third night came. They showed up again with nice clothes and a golden ray of light reflected from their bodies. They presented their wishes to King **Pimpisa** and then vanished.



ដោយសំអាងលើបុគ្គលាធិដ្ឋាននេះហើយ ទើបនៅប្រទេសកម្ពុជាពុទ្ធសាសនិកទាំងឡាយ ឱ្យតែដល់រដូវវស្សាគឺចាប់ពីថ្ងៃ១រោចដល់ថ្ងៃ១៥រោចខែភទ្របទ គេនាំគ្នាទៅវត្តចាត់ចែងជាទាន មានបាយទឹកនំចំណី គ្រឿងស្លៀកដណ្តប់ប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសជូនដល់ក្រុមញាតិរបស់ខ្លួនដែលបានចែកឋានទៅ ។ ពិធីនេះត្រូវបានគេហៅថាពិធីបុណ្យ**កាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះឯង** ។

Because of this, Buddhists in Cambodia go to pagodas to make offerings made up of food and clothing to monks, dedicated to their deceased relatives when the rainy season comes, from the 1st until the 15th day of the waning moon in the 10th lunar month. This is called **Kan Ben** (offering days) **and Phchum Ben Festival.**

